# លិខិតចូលរួមរំលែកទុក្ខ

## ថ្នាក់ដឹកនាំ និងកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី

សូមគោរពជូន

## លោកស្រី អែម ហៀប (ម្តាយនៃសព) និងក្រុមគ្រួសារ នៃសពព្រឹទ្ធបាលឯក សួន រ៉េន

ជាទីគោរពរាប់អាន!

ថ្នាក់ដឹកនាំ និងកម្មករនិយោជិត ធនាគារ អេស៊ីលីដា ភីអិលស៊ី ទាំងអស់ មានសេចក្តីសង្វេគ ស្តាយស្រណោះ ឥតឧបមា ដោយបានទទួលដំណឹងថា **លោកព្រឹទ្ធបាលឯក សួន រ៉េន** យោធិនស្នេហាជាតិដ៏អង់អាចក្លាហាន នៅក្នុងកិច្ចការការពារអធិបតេយ្យភាព បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា បានទទួលមរណភាពក្នុងជន្មាយុ ៤៧ឆ្នាំ នាព្រឹកថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២៥។

យើងខ្ញុំសូមចូលរួមរំលែកមរណទុក្ខដ៏ក្រៀមក្រំសោកស្តាយនេះ ជាមួយក្រុមគ្រួសារ និងក្រុមញាតិសាលោហិត ចំពោះការបាត់បង់ **លោកព្រឹទ្ធបាលឯក សួន រ៉េន** ជាការបាត់បង់នូវកូនប្រុស បងប្រុស ប្អូនប្រុសជាទីស្រឡាញ់ ប្រកបដោយព្រហ្មវិហារធម៌ចំពោះ ក្រុមគ្រួសារ ហើយក៏ជាការបាត់បង់នូវយោធិនស្នេហាជាតិ ដែលបានលះបង់អស់ពីកម្លាំងកាយចិត្តបញ្ញាស្មារតី និងធ្វើពលិកម្ម ដើម្បីបុព្វហេតុ ជាតិ សាសនា ព្រះមហាក្សត្រ។

យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ សូមវិញ្ញាណក្ខន្ធ **លោកព្រឹទ្ធបាលឯក សួន រ៉េន** បានចាប់បដិសន្ធិក្នុងសុខគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

ទន្ទឹមនឹងនេះ ធនាគារ អេស៊ីលីដា ភីអិលស៊ី សូមចូលរួមបុណ្យសពនូវថវិកា ចំនួនប្រាំបីលានរៀល តាមរយៈគណនីនៃក្រុមគ្រួសារសព មាននៅជាមួយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ដូចខាងក្រោម:

- ឈ្មោះគណនី អែម ហៀប
- លេខគណនីប្រាក់រៀល 3493-05887803-20
- លេខគណនីប្រាក់ដុល្លារ 3493-05887803-19

អែម ហៀប
Merchant ID : 25819635

អែម ហៀប
Merchant ID : 25819635

សូម ក្រុមគ្រួសារ និងក្រុមញាតិសាលោហិត មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងជ្រាលជ្រៅបំផុត អំពីយើងខ្ញុំ។

ថ្ងៃសុក្រ ៤កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥

**ធនាគារ អេស៊ីលីដា ភីអិលស៊ី**

ធនាគារ អេស៊ីលីដា ភីអិលស៊ី ACLEDA BANK PLC.

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP